**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១៥៥ អនក្រ.បក

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹតលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ចុះថ្ងៃទី៣០ខែធ្នូឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦
-យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាលកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូន ឯកឧត្តមទេសរដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចរចានិងចុះហត្ថលេខា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ជាមួយតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន លើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស ដែលរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនផ្តល់អោយរាជរដ្ឋាភិបាលកម្ពុជា នូវឥណទានឥតការប្រាក់ ចំនួន ១០០.០០០.០០០ យ័នចិន ( មួយរយលានយ័នចិន) ។

ក្នុងករណីដែលឯកឧត្តម **គាត ឈន់** មានធុរៈជាយថាហេតុឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន ។

អាស្រ័យហេតុនេះ **សម្តេចនាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជាដោយមានសិទ្ធិពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូនបានចុះហត្ថលេខាលើ **សិទ្ធិប្រទាន** នេះ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៦

សែន

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

រាជរដ្ឋាភិបាល
*Royal Government*
N°: 155. D-F.P

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

Phnom Penh, December 22, 2006

## DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia
- Having seen the Royal Decree No. NS / RKT / 0704 /124 dated July 15, 2004, on the Composition of the Royal Government of Cambodia
- Having seen the Royal Decree No. 02 / NS / 94 dated July 20, 1994, on the organization and the functioning of the Council of Ministers
- Having seen the Royal Decree No. NS / RKM /1205/ 040 dated December 30, 2005 on the 2006 Financial Law
- Referring to the request of the Ministry of Economy and Finance

## THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith Full Powers to H.E. Senior Minister **KEAT CHHON**, Minister of Economy and Finance to negotiate and sign on behalf of the Royal Government of Cambodia with the Government of the People's Republic of China, the Agreement on Economic and Technical Cooperation that the Government of the People's Republic of China provides the Royal Government of Cambodia with an interest-free loan of RMB Yuan 100,000,000.00 (one hundred million Renminbi Yuan only). These Powers include the Powers of Delegation.

In witness whereof the undersigned , the Prime Minister of the Kingdom of Cambodia , with full Powers duly entrusted to him , have signed this Delegation of Full Powers.

HUN SEN
Prime Minister